# អង្គការកែច្នៃ និងអនាម័យសហគមន៍

# Community Sanitation and Recycling Organization

**2010 annual report** *in stories*




*... we are working together for our clean environment...*

# បញ្ជីពាក្យកាត់





| | |
|---|---|
| CDC | គណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ |
| CSARO | អង្គការកែច្នៃ និងអនាម័យសហគមន៍ ( ស្ការ៉ូ ) |
| GFC | អង្គការមូលនិធិសាកលសំរាប់កុមារ |
| IDP | កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន |
| MOEP | កម្មវិធីអប់រំផ្សព្វផ្សាយចល័ត |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| SCIAF | មូលនិធិជំនួយអន្តរជាតិរបស់កាតូលីកស្កុតឡែន |
| SHGs | ក្រុមជួយខ្លួនឯង |
| SWM | ការគ្រប់គ្រងសំណល់រឹង |
| SWMP | កម្មវិធីគ្រប់គ្រងសំណល់រឹង |
| UCDP | កម្មវិធីអភិវឌ្ឍន៍សហគមន៍ទីក្រុង |
| WPDC | មណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាម |

*រក្សាសិទ្ធគ្រប់បែបយ៉ាង ២០១០ ដោយ:*

**អង្គការកែច្នៃ និងអនាម័យសហគមន៍**

*សរសេរដោយ:*
**អៀម ភិរម្យ**

*ពិនិត្យ និងកែសំរួលដោយ:*
**សេង សុខសាន្ត**
**ញិប ធី**
Tony Posnett

*រចនាដោយ:*
**អៀម ភិរម្យ**

*បកប្រែដោយ:*
**អៀម ភិរម្យ**

*រូបភាពដោយ:*
**អៀម ភិរម្យ**
**ក្រុមការងាររបស់ស្ការ៉ូ**

*បោះពុម្ព ដោយ:*
**រោងបោះពុម្ពជាតិ**

# LIST OF ACRONYMS

| | |
|---|---|
| **CDC** | Community Development Committee |
| **CSARO** | Community Sanitation and Recycling Organization |
| **GFC** | The Global Fund for Children |
| **IDP** | Institutional Development Program |
| **MOEP** | Mobile Outreach Education Program |
| **NGO** | Non-governmental Organization |
| **SCIAF** | Scottish Catholic International Aid Fund |
| **SHGs** | Self-help Groups |
| **SWM** | Solid Waste Management |
| **SWMP** | Solid Waste Management Program |
| **UCDP** | Urban Community Development Program |
| **WPDC** | Waste Picker Development Center |



**Community Sanitation and Recycling Organization**

©2010
**Community Sanitation and Recycling Organization**

*Writer*
**Eam Phyrom**

*Proofreaders and editors*
**Seng Soksan**
**Nhep Thy**
**Tony Posnett**

*Design and Layout*
**Eam Phyrom**

*Translator*
**Eam Phyrom**

*Photographs*
**Eam Phyrom**
**Courtesy of CSARO Staffs**

*Printed by*
**National Printing House**

# មាតិកា


- បញ្ជីពាក្យកាត់ ទំព័រ ២
- មាតិកា ទំព័រ ៤
- សេចក្តីថ្លែងអំណរគុណ ទំព័រ ៦
- សារលិខិតរបស់លោកនាយកប្រតិបត្តិអង្គការស្ការ៉ូ ទំព័រ ៨
- អំពីស្ការ៉ូ ទំព័រ ១០
- កម្មវិធីរបស់ស្ការ៉ូ ទំព័រ ១២
- សាច់រឿង ទំព័រ ១៤
    - *ការផ្តល់ជូនតិចតួចតែមានឥទ្ធិពលដល់សហគមន៍ទាំងមូល* ទំព័រ ១៤
    - *ជួយប្រជាពលរដ្ឋផង ជួយបរិស្ថានផង* ទំព័រ ២០
    - *ការនាំមកនូវក្តីសង្ឃឹមដល់កុមាររើសសំរាម* ទំព័រ ២៦
    - *ស្ថាប័នរឹងមាំតាមរយៈការពង្រឹងកម្មវិធីអភិវឌ្ឍន៍ស្ថាប័ន* ទំព័រ ៣០
- បទពិសោធន៍ដែលទទួលបាន បញ្ហាប្រឈម និងទិសដៅទៅអនាគត ទំព័រ ៣៦
- បុគ្គលិករបស់ស្ការ៉ូ ទំព័រ ៣២
- ស្ថានភាពហិរញ្ញវត្ថុ ទំព័រ ៣៤
- រូបភាពសកម្មភាពការងារសំខាន់ ៗ របស់ស្ការ៉ូឆ្នាំ ២០១០ ទំព័រ ៣៨
- ម្ចាស់ជំនួយ និងអង្គការជាដៃគូរបស់ស្ការ៉ូ ទំព័រ ៤០




*CSARO staff distributed supporting ... child wast...*



# CONTENTS



*g aid such as rice and foodstuffs to*
*e pickers.*




- List of Acronyms — Page 3
- Contents — Page 5
- Acknowledgements — Page 7
- Message from the Executive Director — Page 9
- About CSARO — Page 11
- CSARO Programs — Page 13
- Feature Stories — Page 15
  - *A Small Provision that Influences the Whole Community* — Page 15
  - *Not One but Both: Helping People and the Environment* — Page 21
  - *Bringing Hope to Child Waste Pickers* — Page 27
  - *A Stronger Organization: The Enhanced IDP* — Page 31
- Lessons Learnt, Challenges and Future Directions — Page 33
- CSARO Staff — Page 35
- Financial Status — Page 37
- Photos of CSARO 2010 Key Activities — Page 39
- CSARO's Donors and Partners — Page 41

# សេចក្តីថ្លែងអំណរគុណ

ដើម្បីឈានទៅដល់ការសំរេចបាននូវសមិទ្ធិផលនេះ គឺពិតជាទាមទារនូវកិច្ចខិតខំប្រឹងប្រែង និងការចូលរួមចំណែកយ៉ាងសកម្មពីសំណាក់បុគ្គលសំខាន់មួយចំនួនរបស់ **ស្ការ៉ូ** ដែលជាអ្នកធ្វើការសំយោគរំលេចឡើងនូវផ្នែកសំខាន់ៗនៃចំណេះដឹងដែលមាន និងបទពិសោធន៍ជាក់ស្តែងរបស់ខ្លួនបញ្ចូលគ្នាដើម្បីឆ្លុះបញ្ចាំងពីជីវិតការងារពិតជាក់ស្តែងរបស់ **ស្ការ៉ូ** ។

យើងខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះលោកនាយកប្រតិបត្តិនៃអង្គការ **ស្ការ៉ូ** គឺលោក **ហេង យ៉ុនគូរ៉ា** ដែលបានផ្តល់នូវមគ្គុទេសន៍ដ៏មានតំលៃ និងផ្តល់ភាពងាយស្រួលដល់ក្រុមក្នុងការប្រមូលយកនូវទិន្នន័យចាំបាច់ និងចូលជួបសម្ភាសន៍ជាមួយនឹងសកម្មជន ក៏ដូចជាអ្នកផ្តល់ពត៌មានសំខាន់ ៗ ដែលឆ្លើយចំទៅនឹងអ្វីដែលពួកយើងចង់បាន។

អំណរគុណជាអនេកកប្បការមួយវិញទៀត គឺសូមគោរពជូនចំពោះ លោក **សេង សុខសាន្ត** និងលោក **ញិប ធី** ចំពោះទស្សនៈវិស័យតម្រង់ទិស និងក្របខ័ណ្ឌគោលគំនិតច្បាស់លាស់ រួមទាំងការផ្តល់នូវចំណេះដឹងដ៏វាងវៃនៃការងាររបស់លោកទាំងពីរ ។ និងសូមអរគុណយ៉ាងខ្លាំងចំពោះ កញ្ញា **អៀម សុខនី** សំរាប់ការសហការដ៏ល្អ និងមតិយោបល់បន្ថែមលើបញ្ហារដ្ឋបាល និងហិរញ្ញវត្ថុរបស់ស្ថាប័ន និងទៅដល់លោក Tony Posnett ក្នុងការកែសំរួលការងារនេះ ។ ការសហការណ៍គាំទ្ររបស់ពួកគាត់បានធ្វើឲ្យរបាយការណ៍នេះលេចជារូបរាងឡើង ។

យើងខ្ញុំក៏មិនអាចបំភ្លេចបានផងដែរនូវបុគ្គលគ្រប់ ៗរូបដែលបានចំណាយពេលវេលាដ៏មានតំលៃជាមួយពួកយើង ក្នុងការចែករំលែកនូវទិន្នន័យ បទពិសោធន៍ដែលគួរអោយចាប់អារម្មណ៍ និងពត៌មានពិស្តារផ្សេង ៗ ។

ចុងក្រោយនេះយើងខ្ញុំសូមផ្ញើរនូវអំណរគុណយ៉ាងខ្លាំងជូនទៅដល់ម្ចាស់ជំនួយទាំងឡាយដែលរួមមាន *MISEREOR, ManosUnidas, មូលនិធិជំនួយអន្តរជាតិរបស់កាតូលិកស្កុតឡែនដ៍ (SCIAF) អង្គការមូលនិធិសាកលសំរាប់កុមារ (GFC)* ក៏ដូចជាដៃគូក្នុងតំបន់របស់ស្ការ៉ូទាំងអស់ដែលបានសហការយ៉ាងល្អ និងផ្តល់ការគាំទ្រជាបន្តបន្ទាប់តាមគ្រប់រូបភាព ។





# ACKNOWLEDGEMENTS





Bringing this publication to fruition required a concerted effort and great contribution from various key persons, who played vital roles in synthesizing their knowledge and practical experiences together to bring to life the work of **CSARO**.

A deep gratitude is specially given to CSARO Executive Director **Mr. Heng Yon Kora**, whose valuable guidance helped the publication team gain access to all the necessary data and be able to approach key actors and informants whose input we needed.

**Mr. Seng Soksan** and **Mr. Nhep Thy** are very much thanked for their support, clear conceptual direction and sharing their detailed knowledge of the work. We would also like to voice a profound thanks **to Ms. Eam Sokny** for her good cooperation and input on financial and administrative issues and to **Mr. Tony Posnett** for his editing. This published work was made possible through these supports.

We are indebted to each and every individual who gave us their valuable time, sharing data, interesting experiences and detailed background information.

Finally, heart-felt thanks is due to our donors namely *MISEREOR, Manos Unidas, Scottish Catholic International Aid Fund (SCIAF) and the Global Fund for Children (GFC)* as well as our collaborating partners for their on-going support and partnership in many areas.

# *សារលិខិតរបស់លោកនាយកប្រតិបត្តិអង្គការស្ការ៉ូ*

ឥទ្ធិពលនៃការប៉ះពាល់ពីការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក បានចាប់ផ្តើមធ្វើឲ្យប្រជាជនកម្ពុជាជួបនឹងការលំបាកកាន់តែច្បាស់ឡើង ៗ នៅពេលដែលវិបត្តិនេះបាននាំដល់ការធ្លាក់ចុះពីការលូតលាស់សេដ្ឋកិច្ចជាតិក្នុងអត្រា ១០ ភាគរយក្នុងឆ្នាំ ២០០៤ ដល់ ២០០៧ ទៅត្រឹមកំរិតមួយទាបបំផុតនៅឆ្នាំ ២០០៩ ហើយបានងើបឡើងបន្តិចបន្តួច មកវិញក្នុងឆ្នាំ ២០១០ ។ វិបត្តិហិរញ្ញវត្ថុ បានក្លាយជាការព្រួយបារម្ភដ៏ធំមួយចំពោះប្រជាជននៅជុំវិញពិភពលោក តែជាពិសេស វានាំនូវការព្រួយបារម្ភយ៉ាងខ្លាំងទៅដល់ប្រជាជនក្រីក្រ និងខ្វះខាតក្នុងប្រទេសកម្ពុជា ដោយសារវាបានបណ្តាលឲ្យប្រជាជនដែលក្រីក្រគ្មានទីពឹងមួយចំនួនធំបាត់បង់ការងាររបស់ខ្លួន នៅចំពេលដែលតំលៃទំនិញ និងគ្រឿងឧបភោគបរិភោគកំពុងតែកើនឡើងជាលំដាប់ ។ នៅពេលដែលប្រជាជនកម្ពុជាបានចាប់ផ្តើមទទួលនូវការប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើង ឆ្នាំ ២០១០ ក៏ជាឆ្នាំដែលប្រទេសដែលកំពុងលូតលាស់ឥតឈប់ឈរមួយនេះ ត្រូវឆ្លើយតបយ៉ាងសកម្មផងដែរ ទៅនឹងការព្រួយបារម្ភលើសន្តិសុខផ្នែកបរិស្ថាន និងបញ្ហាទំនាស់នៅតាមបណ្តោយព្រំដែន ។ កម្ពុជាពិតជាត្រូវការជាចាំបាច់នូវកិច្ចសហការល្អរវាងវិស័យរដ្ឋ សង្គមស៊ីវិល និងវិស័យឯកជនក្នុងដំណើរការអភិវឌ្ឍន៍របស់ខ្លួន ។

នៅពេលដែលប្រទេសកម្ពុជា នៅតែស្ថិតក្នុងជំហរមួយរឹងមាំក្នុងការប្រឈមមុខជាមួយនឹងបញ្ហាទាំងឡាយ **អង្គការ កែច្នៃ និងអនាម័យសហគមន៍ (ស្ការ៉ូ)** ក៏យល់ថាឆ្នាំ ២០១០ ជាឆ្នាំដែលអង្គការនេះបានប្រឈមយ៉ាងសកម្ម និងទទួលបានការរីកចំរើនទៅមុខជាលំដាប់ក្នុងការងារចូលរួមចំណែកពង្រឹងអំណាចដល់ប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង និងក្រុមអ្នករើសសំរាម ដែលបានទទួលផលប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងដោយឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចតាំងពី ឆ្នាំ ២០០៨ មកនោះ ។ អង្គការ **ស្ការ៉ូ** បានសំរេចជាយុទ្ធសាស្ត្រនូវកម្មវិធីធំ ៗ ទាំងបី របស់ខ្លួនក្នុងការនាំឲ្យមានការផ្លាស់ប្តូរពីសហគមន៍ដែលមិនមានអនាម័យ និងមិនទទួលបាននូវសេវាកម្មគ្រប់គ្រាន់ ទៅជាកន្លែងដែលមានបរិស្ថានស្រស់បំព្រងជាង មានសុខាមាលភាពជាង និងមានភាពងាយស្រួលជាងមុន ។ **ស្ការ៉ូ** បានផ្តល់ការកសាងសមត្ថភាពដល់ក្រុមអ្នកទទួលផលផ្ទាល់ ជួយបង្កើនប្រាក់ចំណូលដល់ក្រុមគ្រួសាររបស់គេ និងធ្វើឲ្យប្រសើរឡើងនូវសេវាផ្តល់ការអប់រំដល់ក្មេង ៗ ជំនាន់ក្រោយដែលស្ថិតក្នុងស្ថានភាពយ៉ាប់យ៉ឺនខ្វះទីពឹង ដើម្បីឲ្យពួកគេមានអនាគតល្អប្រកបដោយការលូតលាស់ដ៏សមស្រប ។

ក្នុងឆ្នាំ ២០១០ នេះ អ្នកទទួលផលផ្ទាល់ និងមិនផ្ទាល់ក្នុងចំនួនដ៏ច្រើន បានទទួលការគាំទ្រផ្នែកកសាងសមត្ថភាព ការផ្តល់ជំនាញ ការផ្តល់ទុន ការតស៊ូមតិ និងការចូលរួមសហការណ៍យ៉ាងសកម្មផ្សេង ៗ ទៀត ។ ការគាំទ្របែបនេះ នៅតែជាតំរូវការដ៏ចាំបាច់មិនអាចខ្វះបានសំរាប់ក្រុមគោលដៅ **ស្ការ៉ូ** ដោយសារពួកគេខ្វះនូវឱកាស ដើម្បីទទួលការអប់រំ ។ ពួកគេនឹងអាចឆ្លើយតបប្រកបដោយប្រសិទ្ធិភាពខ្ពស់ ក្នុងការរស់រានរបស់ខ្លួន បន្ទាប់ពីទទួលបានការជួយជ្រោមជ្រែងទាំងឡាយនេះ ។

អង្គការ **ស្ការ៉ូ** មានបំណងធ្វើសមាហរ័នកម្ម និងពង្រឹងកម្មវិធីរបស់ខ្លួន ដើម្បីឆ្លើយតបឲ្យកាន់តែប្រសើរឡើងនៅក្នុង ចំណុចរបត់ជាយុទ្ធសាស្ត្រថ្មីមួយទៅនឹង តំរូវការបច្ចុប្បន្ន និងទៅអនាគតសំរាប់ សន្តិសុខផ្នែកសេដ្ឋ-កិច្ចនៃក្រុមប្រជាពលរដ្ឋក្រីក្រ និងក្រុមអ្នករើសសំរាម និងធានាឲ្យបាននូវបរិស្ថាន ដ៏ល្អប្រកបដោយអនាម័យ សំរាប់ក្រុមគោលដៅរបស់ **ស្ការ៉ូ** ។



*នាយកប្រតិបត្តិអង្គការ ស្ការ៉ូ*
លោក **ហេង យ៉ុនគ្វា**

# MESSAGE FROM THE EXECUTIVE DIRECTOR

The impact of global economic downturn has been suffered in tangible ways by Cambodians as it has led to the decrease from a 10-percent growth rate in 2004-2007 to around almost nothing in 2009, and only a partial recovery during 2010. Financial crisis has been a very deep concern as for many in the world, but particularly for Cambodian poor and disadvantaged groups, causing many of the destitute in the country to lose their jobs and thus be affected negatively by the always rising food and commodity prices. As families in the country started to feel a more severe impact, 2010 represented another hard and demanding year for the changing Cambodia to respond to environmental security concerns and controversial border issues. Cambodia continues to rely on collaboration from other states, civil society and the private sector to develop its society.

As Cambodia remains strong in its work to firmly confront the challenges, **Community Sanitation and Recycling Organization (CSARO)** also had another demanding year in 2010 as it contributed to empowering the urban community people and waste picker groups who are often worse affected by the impacts of economic recession. **CSARO** has worked through its three main strategic programs to contribute to improvements in un-cleaned, un-serviced and low-sanitation areas; creating fresher, healthier living conditions; building capacity of the target beneficiaries to increase their family income and improving education of the underprivileged younger generation for their future well-being and growth.

During 2010, large numbers of direct and indirect beneficiaries significantly benefited from **CSARO**'s people- and community-based approaches that supported capacity building, skill and capital provision, advocacy, collaborative engagement and the like. Such supports are vital to **CSARO** target groups who often had have limited opportunities for education, but respond and develop their own livelihoods so productively as they are given these chances.



**CSARO** is looking to integrate and strengthen its programs and develop them further as it considers future strategies that respond even better to the identified needs for social and economic security of the urban poor and the destitute waste pickers; also ensuring a fresher and cleaner environment with better sanitation for **CSARO's** target populations.



*CSARO Executive Director*
***Mr. Heng Yon Kora***

# អំពី ស្ការូ៖

**អង្គការកែច្នៃ និងអនាម័យសហគមន៍ (ស្ការូ)** គឺជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជាមួយដែលត្រូវបានបង្កើតឡើងក្នុងខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដោយក្រុមអ្នកធ្វើការងារអភិវឌ្ឍន៍មួយចំនួនដែលមានឆន្ទៈក្នុងការធ្វើការកែលំអរបរិស្ថាន និងលើកស្ទួយកំរិតជីវភាពរស់នៅរបស់ប្រជាជនក្រីក្រក្នុងសហគមន៍ទីក្រុងក្នុងប្រទេសកម្ពុជា ។ **ស្ការូ** ជាស្ថាប័នឈានមុខមួយ ដែលបានអនុវត្តនូវយុទ្ធសាស្ត្រចូលរួម ដើម្បីកែលំអរស្ថានភាពក្នុងតំបន់រស់នៅរបស់ប្រជាជនក្រីក្រក្នុងសហគមន៍ទីក្រុង ដែលធម្មតាជាកន្លែងដែលមិនមានផែនការអភិវឌ្ឍន៍ និងមិនទទួលបាននូវការផ្តល់សេវាកម្មចាំបាច់ផ្សេង ៗ ។ **ស្ការូ** ផ្តោតការយកចិត្តទុកដាក់ដល់ការលើកស្ទួយស្ថានភាពរស់នៅ និងការងាររបស់អ្នករើសសំរាមទាំងចាស់ និងក្មេងរាប់ពាន់អ្នក ដែលរស់នៅដោយពឹងផ្អែកលើការរើសសំរាមតាមដងវិថី និងគំនរសំរាមនា នា ។

## ទស្សនៈវិស័យ

សហគមន៍ក្នុងតំបន់ទីក្រុងនានា ដែលប្រជាពលរដ្ឋនិងអ្នករើសសំរាមចេះ ធ្វើការរួមគ្នាក្នុងការកែប្រែតំបន់ សហគមន៍កខ្វក់ទៅជាកន្លែងដែលមានបរិស្ថានស្អាត មានសុវត្ថិភាព និងផាសុខភាពសំរាប់ការរស់នៅ ។ អ្នករើសសំរាមទាំងអស់ធ្វើការងាររួមគ្នា ដើម្បីកែលំអរស្ថានភាពសង្គម និងសេដ្ឋកិច្ចផ្ទាល់របស់ក្រុមពួកគេឲ្យកាន់តែមានភាពប្រសើរឡើង ។



**គោលបំណងទី ២:** ពង្រឹងសិទ្ធិអំណាចដល់ក្រុមជួយខ្លួនឯងឲ្យចេះធ្វើការជាមួយអ្នកសហគមន៍ សំដៅដល់ការអនុវត្តន៍ ប្រពន្ធ័គ្រប់គ្រងសំណល់រឹង ក្នុងន័យធានាឲ្យបាននូវនិរន្តរភាព ។

**គោលបំណងទី ៣:** ជួយអ្នករើសសំរាមក្រីក្រ ឲ្យពង្រឹងស្ថានភាពសុខភាពរបស់ពួកគាត់តាមរយៈ ការផ្តល់ជាការអប់រំក្រៅប្រព័ន្ធ លើបញ្ហាសុខភាព សុវត្ថិភាព និងអនាម័យសហគមន៍ ។

**គោលបំណងទី ៤:** **ស្ការូ** មាននូវប្រព័ន្ធការងារផ្ទៃក្នុង ដែលអាចបង្កើននូវប្រសិទ្ធិភាព និងប្រសិទ្ធិផលខ្ពស់នៃការអនុវត្តន៍កម្មវិធីរបស់ខ្លួន ។

## បេសកកម្ម

លើកទឹកចិត្ត ដល់ប្រជាពលរដ្ឋរស់ក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង ដើម្បីការលើកកំពស់សមត្ថភាព និងស្ថានភាពសេដ្ឋកិច្ច សង្គម និង បរិស្ថានរបស់ពួកគេ ។

## គោលដៅ

ការផ្តល់សិទ្ធិអំណាច ដល់ប្រជាសហគមន៍ក្រីក្រក្នុងទីក្រុង និងអ្នករើសសំរាម ឲ្យពួកគេអាចធ្វើការសហការណ៍គ្នា ជួយធ្វើឲ្យបរិស្ថានរស់នៅល្អ និងពង្រឹងស្ថានភាព សេដ្ឋកិច្ចគ្រួសាររបស់ពួកគេឲ្យប្រសើរឡើង ប្រកបដោយនិរន្តរភាព នាពេលអនាគត ។

## គោលបំណងកម្មវិធីរបស់អង្គការស្ការូ

**គោលបំណងទី ១:** ពង្រឹងសិទ្ធិអំណាច និងសមត្ថភាពដល់ប្រជាសហគមន៍ទីក្រុង ដើម្បីឲ្យចេះធ្វើការអភិវឌ្ឍន៍ដោយខ្លួនឯង និងអាចចូលរួមបង្កើតឲ្យបាននូវបរិស្ថានមួយពោរពេញដោយផាសុខភាព និងភាពបរិសុទ្ធ ប្រកបដោយនិរន្តរភាព ។ លើកកំពស់ស្ថានភាព សេដ្ឋកិច្ច និងសង្គម របស់ក្រុមអ្នករើសសំរាមជាក្រុមគោលដៅ ។



# ABOUT CSARO



**Community Sanitation and Recycling Organization (CSARO)** is a Cambodian non-governmental organization (NGO), established in February 1997 by a group of development workers committed to improving the environment and living conditions of the urban poor in Cambodia. **CSARO** is a leader in the use of participatory models to improve conditions in the areas where the urban poor live which are often unplanned and un-serviced parts of the city. A special focus of **CSARO**'s work is improving the living and working conditions of the thousands of adult and child waste pickers who make their living by sorting through rubbish on the street and from piles of garbage.

## *VISION*

Urban communities where residents and waste pickers work together to transform slum areas into clean, safe and healthy places to live, and where waste pickers work together to improve their social and economic conditions.



## *MISSION*

To encourage and motivate urban poor people to improve their capacity and their environmental, social and economic conditions

## *GOAL*

Empowered urban communities and waste pickers, cooperating to improve their environment and creating better family economic conditions for a sustainable future



## *CSARO PROGRAM OBJECTIVES*

*Objective1:* Empowered waste pickers and target communities handle their own development to improve social and economic conditions and enhance their environment in a sustainable manner.

***Objective2:*** Empowered Self-Help Groups work with target communities and local authorities to implement a Solid Waste Management System tha improves the local environment in a sustainable manner.

***Objective3:*** Waste pickers and community residents have improved health through non-formal education on health, safety and community sanitation.

***Objective4:*** CSARO has stronger internal systems that improve the effectiveness and efficiency of its program implementation.

# កម្មវិធីរបស់ ស្ការ៉ូ

## កម្មវិធីគ្រប់គ្រងសំណល់រឹង

**កម្មវិធីគ្រប់គ្រងសំណល់រឹង**ផ្តោតជាចំបងទៅលើ ផលិតផលជីកំប៉ុស្ត ដែលត្រូវបានផលិត ប្រើប្រាស់ និងលក់ដោយក្រុមអ្នករើសសំរាម និង ប្រជាពលរដ្ឋក្រីក្រ និងផ្តោតលើការងារប្រមូលសំរាមបឋមរបស់ក្រុម ជួយខ្លួនឯង ក្នុងន័យលើកកំពស់ស្ថានភាពរស់នៅ ។ ឆ្នាំ ២០១០ នេះ **កម្មវិធីគ្រប់គ្រងសំណល់រឹង** បានផ្តល់នូវវគ្គបណ្តុះបណ្តាលផលិតជីកំប៉ុស្ត ទៅអ្នករើសសំរាមក្នុងចំនួនដ៏ច្រើនបន្ថែមទៀត និងអាចផលិតបានជីកំប៉ុស្តចំនួន **១២.១៨០** តោន ហើយក៏បានផ្តល់ឱកាសឲ្យប្រជាពលរដ្ឋមួយចំនួនអាច ស្នាក់អាស្រ័យនូវមណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាមរបស់ **ស្ការ៉ូ** ។ ការប្រមូលសំរាមបឋមពីតាមផ្ទះក៏ជួយយ៉ាងច្រើនលើផ្នែកអនាម័យ និងបរិស្ថានល្អ ។ ដូចនេះ **កម្មវិធីគ្រប់គ្រងសំណល់រឹង** បានចូលរួមចំណែកគួរឲ្យកត់សំគាល់ដល់ការពង្រឹងសមត្ថភាពអ្នករើសសំរាមទាំងអស់ និងផ្តល់នូវឱកាសសំរាប់ការចូលរួមរបស់ពួកគេក្នុងការធានានូវនិរន្តរភាពនៃបរិស្ថានល្អ ។ នៅពេលដែលពួកគេចាប់យកឱកាសសិក្សាពីរបៀបផលិតជីកំប៉ុសពី **ស្ការ៉ូ** ពួកគេអាចបន្តចំណេះដឹងនេះទៅបងប្អូន ញាតិជិតខាង និងអ្នកដទៃផ្សេងទៀត ។

## កម្មវិធីអភិវឌ្ឍន៍សហគមន៍ទីក្រុង

កម្មវិធីអភិវឌ្ឍន៍សហគមន៍ទីក្រុងដែលផ្តោតសកម្មភាពការងារទៅលើ សហគមន៍ក្រីក្រ ក្នុងតំបន់ទីក្រុងដូចជាសហគមន៍ **សែនសុខ សាមគ្គី** និង **ស្ទឹងមានជ័យ** បានបន្តផ្តល់ជូនក្នុងឆ្នាំការងារ ២០១០ នេះ នូវការប្រជុំគណកម្មាធិការអភិវឌ្ឍន៍សហគមន៍ ៦ ដង បង្កើតនូវការផ្លាស់ប្តូរទស្សនៈកិច្ចសិក្សា ១ ដង សិក្ខាសាលា បណ្តុះបណ្តាលពីការអភិវឌ្ឍន៍សហគមន៍ ២ដង ការប្រជុំក្រុមអ្នករើសសំរាម ៦ ដង និងវគ្គផ្សព្វផ្សាយការយល់ដឹងផ្សេង ៗ ទៀត ។ កម្មវិធី នេះបានផ្តល់នូវជំនាញទៅគណកម្មាធិការអភិវឌ្ឍន៍សហគមន៍ អ្នករើសសំរាម និងប្រជាពលរដ្ឋក្នុងសហគមន៍ ក្នុងការចាប់ផ្តើមចលនាអភិវឌ្ឍន៍សហគមន៍ បន្តការចូលរួមយ៉ាងផុលផុសក្នុងកិច្ចអភិវឌ្ឍន៍ និងចេះកែច្នៃសំរាម ដែលគ្មានតម្លៃយ៉ាងស្ទាត់ជំនាញដើម្បីទ្រទ្រង់ជីវភាពគ្រួសារបន្ថែម ។ **កម្មវិធីអភិវឌ្ឍន៍សហគមន៍ទីក្រុង**របស់ **ស្ការ៉ូ** បានធ្វើការពង្រឹងហេដ្ឋារចនាសម្ព័ន្ធរបស់សហគមន៍គោលដៅ តាមរយៈការគាំទ្រផ្នែកបច្ចេកទេសអភិវឌ្ឍន៍ ការគាំទ្រស្មារតី និងថវិការបដិភាគដើម្បីកសាងផ្លូវ ឬប្រពន្ធ័លូ ផ្សេង ៗ ។ ប្រជាពលរដ្ឋប្រមាណ **៨.២០០** នាក់ ជាអ្នកទទួលផលពីគំនិតផ្តួចផ្តើមនៃការកែលំអរហេដ្ឋារចនាសម្ពន្ធ័ និងការផ្តល់ជំនាញការកែច្នៃរបស់ ស្ការ៉ូ ។

## កម្មវិធីអប់រំផ្សព្វផ្សាយចល័ត

តាមរយៈការស្វះស្វែងគាំទ្រដល់កុមារ ដែលសុទ្ធសឹងជាកុមាររើសសំរាមក្នុងសហគមន៍អ្នករើសសំរាម **កម្មវិធីអប់រំផ្សព្វផ្សាយចល័ត** ត្រូវបានបង្កើតឡើងជាពិសេស ដើម្បីផ្តល់ឱកាសដល់កុមាររើសសំរាម និងកុមារីជំទង់ជាអ្នករើសសំរាម ដែលជាជនងាយរងគ្រោះថ្នាក់ និងមិនទទួលបាននូវការយកចិត្តទុកដាក់ ។ ពួកគេអាចងាយនឹងបាត់បង់ការសិក្សាអប់រំណាស់ ដូច្នោះ **ស្ការ៉ូ** ក៏ផ្តល់លទ្ធភាពឲ្យពួកគេចូលរួមក្នុង វគ្គការអប់រំក្រៅប្រពន្ធ័ របស់អង្គការនេះ ដោយផ្តល់ឲ្យនូវចំណេះដឹងផ្នែកអក្សរ នពន្ធ អនាម័យខ្លួនប្រាណ ការព្យាបាលរបួស និងសិទ្ធកុមារ -ល- ។ **ស្ការ៉ូ** ក៏បានផ្តល់ការប្រឹក្សាសំរាប់កុមារីជំទង់លើផ្នែកសុខភាពស្ត្រី នៅតាមកន្លែងណាត់ជួបដែលបានកំណត់ជាមុន ។ ដោយមានការគាំទ្របែបនេះ បន្ថែមទៅលើការផ្តល់អ្វី ដែលហៅថា *ជំនួយបឋម* និងការគាំទ្រផ្លូវចិត្តពីស្ការ៉ូ កុមាររើសសំរាមបានទទួលនូវចំណេះដឹង និងចំណេះធ្វើដែលចាំបាច់ អាចឲ្យពួកគេត្រឡប់ទៅយកចិត្តទុកដាក់ពីតំលៃនៃសុខភាព និងការអប់រំវិញ។ ជារួម កុមាររើសសំរាម និងកុមារីជំទង់រើសសំរាមចំនួន ប្រមាណ **២៥០** នាក់ ដែលក្នុងនោះមានកុមារីប្រមាណ **៩៤** នាក់ ជាអ្នកទទួលផលផ្ទាល់ពីកម្មវិធី និងមានអ្នកទទួលផលប្រយោល ជាច្រើនទៀត ក្នុងឆ្នាំ ២០១០ នេះពីការបង្រៀនត ៗ គ្នា។

## កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន

មិនខុសពីស្ថាប័នដទៃទៀតឡើយ អង្គការ **ស្ការ៉ូ** បានធ្វើការកសាងសមត្ថភាពបុគ្គលិក និងជួយជំរុញឲ្យមានទំនាក់ទំនងនិងកិច្ចសហការណ៍ល្អ និងប្រព័ន្ធការងារជាក្រុមរវាងបុគ្គលិកទាំងអស់តាមរយៈ **កម្មវិធីអភិវឌ្ឍន៍ស្ថាបន័** របស់ខ្លួន ។ ការបណ្តុះបណ្តាលមួយចំនួនដូចជា *វិធីសាស្ត្រផ្តោតលើសិទ្ធិ ការគ្រប់គ្រងហិរញ្ញវត្ថុ និងវគ្គភាសាអង់គ្លេសខ្លីៗ* ត្រូវបានផ្តល់ជូនដល់បុគ្គលិក ដើម្បីឲ្យពួកគេអាចពង្រឹងនូវជំនាញ និងការមានទំនួលខុសត្រូវរបស់ខ្លួន និងអាចធ្វើការជាមួយគ្នាប្រកបដោយប្រសិទ្ធិភាពនិងស្មារតីក្រុម។កម្មវិធីនេះក៏រាប់បញ្ចូលនូវការចែករំលែករបស់សមាជិកគ្រប់គ្រង និងលោកនាយកប្រតិបត្តិរបស់អង្គការ ក្នុងការបំផុសឲ្យមានគំរោងផែនការដែលចាំបាច់ ដល់ការលូតលាស់របស់ស្ថាបន័ទាំងមូល ។ ការធ្វើសិក្ខាសាលាកសាងផែនការយុទ្ធសាស្ត្រ សំរាប់ឆ្នាំ ២០១០នេះ បានជួយឲ្យមានទំនាក់ទំនងល្អ និងជំនឿចិត្តទៅលើគ្នាខ្ពស់បន្ថែមទៀតរវាងបុគ្គលិក និងបុគ្គលិក។

# CSARO PROGRAMS

### *SOLID WASTE MANAGEMENT PROGRAM (SWMP)*

The **SWM** Program centers mainly on compost -- made, used and sold by waste pickers and poor community resident groups. As well as improving livelihoods, it seeks to create a cleaner, healthier environment through an effective primary waste collection process. In 2010, SWMP provided training on compost making skills to many waste pickers, produced *12,180* kilograms of compost, and gave access to a number of residents through the waste picker development centre (**WPDC**). Thus, **SWMP** contributed noticeably to enhancing the capacity of waste pickers and giving more opportunity for their participation in the sustainable environmental development. Once they took the opportunity to learn compost-producing methods from **CSARO**, those target groups could further transfer the knowledge and know-how to their relations, neighbors or others.

### *URBAN COMMUNITY DEVELOMENT PROGRAM (UCDP)*

Focusing on the urban poor communities of Sen Sok, Samaky and Stung Meanchey in Phnom Penh city, the **UCDP** in 2010 worked to support 6 **CDC** meetings, 1 exchange visit, 2 community development training workshops, 6 waste picker meetings and various awareness raising sessions. The program transferred skills to the **CDCs**, waste pickers and poor community residents so they could collaboratively work on infrastructure development independently and vigorously engage in their community improvement process, as well as recycling 'worthless waste' into various products that could support their family income. **CSARO's UCDP** has enhanced target communities' road and sewer drainage systems through technical, mental and financial supports for construction and/or repair. Around *8,200* community people have benefited from the **UCDP** initiatives.

### *MOBILE OUTREACH EDUCATION PROGRAM (MOEP)*

Supporting some of the most vulnerable waste pickers in Phnom Penh, the **MOEP** was specially designed to offer better life chances to child and female teen waste pickers who were susceptible to many dangers and deprivations from a life of collecting waste. These children, who are likely to miss out on education, are offered non-formal education sessions on literacy and math, personal hygiene, injury treatment, child rights and other topics. Counseling sessions are also held at various specific contact points particularly for girls. With such supports from **CSARO**, additional to the so-called First Aid, child waste pickers have the opportunity to learn new skills and oftem turn to see the value of health and education. In total, a number of 250 child waste pickers, 94 of whom were female, were direct beneficiaries from the program, with many more benefiting indirectly through peer to peer sharing of knowledge.

### *INSTITUTIONAL DEVELOPMENT PROGRAM (IDP)*

Like many other institutions, **CSARO** continually works on building its staff capacity through the **Institutional Development Program (IDP)** improving communication, systems and teamwork. Various training courses, were provided to staff to enhance their existing skills and further advance their knowledge including Using a Rights-based Approach, Financial Management and English. In addition the board and the ED, with participation from the staff, continued to develop plans for the future growth and development of the institution. The Staff Retreat for year 2010 also provided a great opportunity for enhanced relationships and built trust.





# ការផ្តល់ជូនតិចតួច តែមានឥទ្ធិពលដល់សហគមន៍ទាំងមូល

## *សែន សុខ និង ផ្លូវថ្មីមួយខ្សែ*

ការខ្វះជំនាញជាមូលដ្ឋាន និងភាពមិនសកម្មក្នុងកិច្ចសហការណ៍ រួមផ្សំនឹងភាពខ្វះចន្លោះក្នុងការផ្តល់សេវាកម្ម ដូចជាផ្នែកអនាម័យទឹកស្អាត ការពិនិត្យសុខភាព ហេដ្ឋារចនាសម្ព័ន្ធ និងការពង្រឹងវិស័យអប់រំ បានធ្វើឲ្យមានភាពពិបាកជាខ្លាំងដល់ការរស់រានរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ក្រីក្រ ។ ការស្រមៃចង់បានការលូតលាស់ និង ការអភិវឌ្ឍន៍ហាក់បីដូចជា គោលដៅមួយដែលពិបាកយ៉ាងខ្លាំងក្នុងការឈានទៅដល់ដែលធ្វើឲ្យប្រជាពលរដ្ឋមិនមានទឹកចិត្តចង់ចាត់វិធានការ ផ្សេង ៗ ក្នុងការតទល់ដោះស្រាយនូវបញ្ហាដែលពួកគេបានជួបប្រទះ ។

*ប្រជាជនរស់នៅ **សែន សុខ** យើងនេះជួបការលំបាកណាស់ តាំងពីកកើតសហគមន៍នេះក្នុងឆ្នាំ ២០០១ មក ដោយសារយើងមិនដឹងថាត្រូវធ្វើយ៉ាងដូចម្តេច។ ក៏ជីវិតជីវភាពរបស់ពួកគាត់ទាបណាស់ ហើយពួកគាត់មិន មានទឹកចិត្តក្នុងការចាប់ផ្តើមចូលរួមសកម្មក្នុងការងារអភិវឌ្ឍន៍ឡើយ៖* នេះបើតាមសំដី **អ្នកស្រី ខ្លូត ផល្លា** ដែលជាអ្នកធ្វើការងារសង្គមដ៏សកម្មម្នាក់ ហើយក៏ជាប្រជាជនមួយរូបនៅសហគមន៍ សែន សុខ ។ អ្នកស្រីបានបន្ថែមថា៖ *យើងត្រូវការផ្លូវ និងលូថ្មី ព្រោះក្នុងរដូវវស្សាម្តង ៗ ទឹកលិច មានភក់ជ្រាំ និងមានខ្លិនស្អុយពិបាកធ្វើដំណើរណាស់ ។ ហើយ* នេះគឺគ្រាន់តែជាឧទាហរណ៍មួយ ក្នុងចំណោមឧទាហរណ៍ជាច្រើនដែលប្រជាពលរដ្ឋបានរអ៊ូរទាំដោយត្រង់ ៗ ទៅលើការរស់នៅរបស់ពួកគាត់ក្នុងសហគមន៍ខ្វះការអភិវឌ្ឍន៍។

ក្នុងស្ថានភាពនេះ **អង្គការ ស្ការ៉ូ** ជឿជាក់ថាការអនុវត្តន៍នូវ វិធីសាស្ត្រដោយអាស្រ័យលើការចូលរួមរបស់ប្រជាពលរដ្ឋផ្ទាល់ ក្នុងការធានាឲ្យបាននូវការអភិវឌ្ឍន៍សហគមន៍ដោយមាននិរន្តរភាព ជាវិធីដែលនឹងមានប្រសិទ្ធិភាព និងសុវត្ថិភាពខ្ពស់បំផុត ដោយសារការតំរង់ទិសដៅ និងដំណើរការរបស់វិធីសាស្ត្រនេះអាចលើកទឹកចិត្តប្រជាពលរដ្ឋសហគមន៍ឲ្យអាចកំណត់បាននូវតំរូវការ និងបញ្ហាប្រឈមរបស់ពួកគេ ដែលនាំឲ្យពួកគេអាចរួមសហការគ្នាក្នុងការដោះស្រាយបញ្ហាដោយ ខ្លួនគេផ្ទាល់ ។ មិនត្រឹមតែប៉ុណ្ណោះ វាផ្តល់អំណាចឲ្យសមាជិករបស់សហគមន៍ នូវសមត្ថភាពក្នុងការតស៊ូមតិទាមទារការគាំទ្រដ៏មានប្រសិទ្ធភាព និងការចូលរួមពីសំណាក់អជ្ញាធរក្នុងតំបន់ អ្នកទទួលផល និងស្ថាបន័ដែលពាក់ពន្ធ័ផ្សេង ៗ ។

ចាប់តាំងពីពេលដែល **ស្ការ៉ូ** ឈានជើងចូលដល់ការអនុវត្តនូវវិធីសាស្ត្រនេះ **ស្ការ៉ូ** បានសំរេចនូវសមិទ្ធិផលជោគជ័យមួយចំនួនដោយបានសំរេចការសាងសង់ផ្លូវ ក៏ដូចជាការសាងសង់ប្រពន្ធ័លូបង្ហូរទឹកស្អុយដល់សហគមន៍មួយចំនួនធំ ។ ជាក់ស្តែង ក្នុងឆ្នាំ ២០១០ នេះ **ស្ការ៉ូ** បានសំរេចសាងសង់នូវផ្លូវមួយខ្សែប្រវែង ១៥០ ម៉ែត្រ សំរាប់សហគមន៍ សែនសុខ ២ ។ **លោក សេក ប៊ុយ** អាយុ ៤២ឆ្នាំ ជាប្រជាជនក្នុងសហគមន៍ **សែន សុខ** ក៏ជាអ្នកទទួលផលម្នាក់ពីសំណង់ផ្លូវមួយខ្សែនេះ បានបង្ហាញនូវទឹកចិត្តរំភើបរីករាយរបស់គាត់ថា៖

*ខ្ញុំមានអារម្មណ៍ថាផ្លូវថ្មីនេះពិតជាអាចជួយ ពួកយើងច្រើនណាស់ ។ គ្រួសាររបស់ខ្ញុំ និង ខ្ញុំ សប្បាយចិត្តខ្លាំងណាស់ ។ ជំនួសមុខឲ្យប្រជាពលរដ្ឋក្នុង សហគមន៍ទាំងមូលខ្ញុំចង់ សំដែងការអរគុណជាអនេគកប្បការ ចំពោះ អង្គការ ស្ការ៉ូ ដែលផ្តល់ការគាំទ្រយ៉ាងខ្លាំងជាបន្តបន្ទាប់ប្រកបដោយកិច្ចសហការល្អ និងការផ្តល់ឱកាសដល់ការលូតលាស់របស់សហគមន៍តាមរយៈ វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពដូចជាការរៀនពី ការសរសេរសំណើរសុំជំនួយ ការកសាងក្រុម ការដឹកនាំជាដើម ។ ឥលូវនេះ យើងចេះប្រមូលមូលនិធិ និងធ្វើកិច្ចសហប្រតិបត្តិការ ជាមួយនឹងអជ្ញាធរក្នុងតំបន់បានយ៉ាងប្រសើរ ។*

ផ្លូវថ្មីមួយខ្សែនេះចំណាយរយៈពេលប្រមាណ ៣ ខែ តាំងពី ខែមិថុនា ដល់ខែ សីហា ឆ្នាំ ២០១០ ហើយវាក៏ជាសមិទ្ធិផលថ្មីស្រឡាង មួយក្នុងឆ្នាំថ្មីនេះរបស់ **ស្ការ៉ូ** ក្នុងការងារចូលរួមចំណែកកសាងសហគមន៍ដោយមានការ លើកទឹកចិត្ត ការចូលរួម និងការជំរុញឲ្យមានការស្រលាញ់បរិស្ថានល្អ ។ បើតាមការប៉ាន់ប្រមាណផ្លូវមួយខ្សែនេះមានអ្នកទទួលផលសរុបប្រមាណ ១៣១ គ្រួសារតាមរយៈការធ្វើដំណើរទៅមក ក៏ដូចជាការប្រាស្រយ័ទាក់ទងផ្សេង ៗ ។ ក្មេង ៗ ក៏អាចប្រើផ្លូវថ្មីនេះនៅពេលដែលពួកគេទៅសាលារៀន ហើយក៏មិនមានបញ្ហាការឆ្លងជំងឺច្រើនទៀតដូចមុនដែរ ។ តាមរយៈការផ្តួចផ្តើមគំនិត និងសកម្មភាពផ្តល់ជាទុនក៏ដូចជាការលើកទឹកចិត្តឲ្យមានការប្តេចជ្ញាខ្ពស់ បូករួមនឹងការព្យាយាម និងការងារយ៉ាងសកម្មពីសហគមន៍ផងដែរនោះ **ស្ការ៉ូ** បានធ្វើឲ្យសមិទ្ធិផលតិចតួច តែប្រកបដោយវិសេសភាព បែបនេះលេចជារូបរាងឡើង។



# A Small Provision That Influences the Whole Community

## *SEN SOK and ITS NEW ROAD*

Lack of fundamental skills, little cooperation and poor services in such areas as water sanitation, health care, infrastructure and education make life difficult for urban poor community residents. The idea of growth and development sounds as if it is a very hard-to-reach destination, which has discouraged many people from taking action to confront their own problems.

*"It has been totally hard for life in Sen Sok since its establishment in 2001 as people do not have clear outlooks for development despite a great desire for it. Their living standard is low and so they don't want to take part in the development process,"* claimed Mrs. Khloth Phalla, an active social worker and a resident of Sen Sok community. She added: *"In rainy season, roads inundated and plastered in stinking mud cause a lot of hardships."* This is just one of very many examples of how community people frankly complain about their lives in their underprivileged communities.

**CSARO** believes that applying a people-centered approach to ensure sustainable community development is a secure and productive process that stimulates the community residents to learn to identify their own needs, raise challenging issues and hence collaboratively solve problems by themselves. It furthermore empowers the community members to be capable of advocating their rights and needs to others, increasing the participation of the local authorities in charge as well as other related bodies.

Through implementing this people-centered model, **CSARO** has successfully facilitated the construction and repair of a number of roads and sewer drainage systems in the target communities.

In 2010, the supports from **CSARO** made a 150-meter road possible for the community of Sen Sok 2. **Mr. Sek Buy**, 42, Sen Sok village chief and one of the beneficiaries expressed his pleasure:



*"I feel the new road will help us a lot. My family and I am very happy with it. I would love, on behalf of my community at large, to voice out my sincere thanks to CSARO for its strong, continuing supports, good cooperation and the provision of opportunity for growth via capacity building sessions such as Leadership, Team Building, Proposal Writing, etc. We are now able to raise funds and make good cooperation with the local authorities."*

The road took 3 months to be finished – from June to August 2010, and represents a significant achievement in building a community with self-motivation, participation, and clean environment. It is estimated that at least 131 families dwelling in Sen Sok 2 commune will be the direct beneficiaries of this project as they make use of the newly-constructed road. It means children can use the roads when they go to school, adults can more easily go to work or to sell things ar the market, and there is less opportunity for disease to spread. By some simple facilitation of initial ideas and action, as well as encouraging commitment, solidarity and hard work from the community, **CSARO** has enabled the community to achieve this small but very significant change.



*Training providid to CDC members at CSARO center in Khmourch commune, Sen Sok district.*

# លូបង្ហូរទឹកស្អុយដែលកើតចេញពីកិច្ចសហការល្អ



*លូបង្ហូរទឹកស្អុយចាស់ស្ទះដោយសារសំរាមរលួយស្អុយ ដែលធ្វើឲ្យប៉ះពាល់ដល់សហគមន៍*

បន្ទាប់ពីបានទទួលនូវការបណ្តុះបណ្តាលជំនាញ និងការផ្សព្វផ្សាយចំណេះដឹងលើការងារអភិវឌ្ឍន៍សហគមន៍ ប្រជាពលរដ្ឋក៏ចាប់ផ្តើមកំណត់នូវបញ្ហាប្រឈមជាអាទិភាពក្នុងតំបន់រស់នៅរបស់ខ្លួន ហើយក៏ស្វែងរកដំណោះស្រាយដែលមានសក្តានុពល ។ ពួកគាត់ក៏បានកំណត់នូវទំហំសកម្មភាពដែលពួកគាត់អាចធ្វើបាន និងសកម្មភាពដែលពួកគាត់ត្រូវការជំនួយ និងការគាំទ្រពីអាជ្ញាធរក្នុងតំបន់ ឬស្ថាប័នសង្គមស៊ីវិលផ្សេង ៗ ។

នៅរដូវវស្សាជារៀងរាល់ឆ្នាំ សហគមន៍ **សែនសុខ ៤** តែងតែជួបប្រទះនូវភាពអកុសលដោយសារតែទឹកភ្លៀងបានធ្វើឲ្យលិចលង់នៅក្នុងតំបន់នោះ ដែលបណ្តាលឲ្យមនុស្សម្នារងគ្រោះដោយសារជំងឺដែលឆ្លងតាមទឹក និងក្លិនបំពុលមកពីសំរាមរលួយដែលហូរតាមទឹក ។ ដូចគ្នានោះដែរ វាមានភាពពិបាកសំរាប់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ និងការប្រាស្រ័យទាក់ទងគ្នាក្នុងអំឡុងពេលនោះណាស់ ។ ដូច្នេះហើយនៅពេលដែលប្រជាជនចាប់ផ្តើមធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហាពួកគាត់ ដោយបានសំរេចចិត្តធ្វើគំរោងសំណើរមួយដើម្បីប្រមូលមូលនិធិ (តាមគោលការណ៍ ៥០-៥០) ពី អង្គការ **ស្តារ៍** ក៏ដូចជាប្រជាពលរដ្ឋដូចគ្នា និងអាជ្ញាធរទទួលខុសត្រូវ ដើម្បីកសាងនូវប្រពន្ធ័លូបង្ហូរទឹកស្អុយ ដែលអាចបញ្ចៀសសហគមន៍ពីការលិច និងបរិស្ថានមិន បរិសុទ្ធដូចឆ្នាំមុន ៗ ។

**លោក កង ចក្រាវុធ** ដែលជាសមាជិកក្នុងសហគមន៍ **សែន សុខ** ម្នាក់ បានលើកឡើងនូវការបារម្ភរបស់គាត់ថា៖ *វាមានការលំបាកណាស់នៅពេលមានភ្លៀង ដោយសារទឹកដែលនៅដក់នៅតាមដងផ្លូវធ្វើឲ្យពួកយើងពិបាកក្នុងការធ្វើដំណើរទៅមក និងវាមានក្លិនស្អុយ។* គាត់ក៏បន្ថែមទៀតថា៖ *ខ្ញុំមានអារម្មណ៍រីករាយណាស់នៅពេលដែលសំណើរនេះ បានទទួលការពិចារណា និងប្រព័ន្ធ័លូទឹកស្អុយនោះនឹងត្រូវកសាងនៅក្នុង សែន សុខ ៤ ។ ខ្ញុំមិនដែលគិតថា អ្នកសហគមន៍ យើងទាំងប៉ុន្មានអាចធ្វើវាបានឡើយ ។*

បន្ទាប់ពីរយៈពេលប្រមាណ ២ ខែ នៃការសហការណ៍របស់ប្រជាពលរដ្ឋក្នុងតំបន់ និងការគាំទ្រពីអាជ្ញាធរ និងស្តារ៍ លូបង្ហូរទឹកស្អុយមួយក៏ត្រូវបានសាងសង់ឡើងយ៉ាងជោគជ័យជំនួសនូវលូចាស់ដែលមានគំនរសំរាមពាសពេញ ហើយធ្វើឲ្យស្ទះទឹកមិនអាចហូរបាន។ ដូចនេះប្រជាពលរដ្ឋមិនចាំបាច់មានការបារម្ភទៀតឡើយ ពីផ្លូវទឹកលិច ក្លិនមិនល្អ និងភក់ជ្រាំនៅរដូវវស្សានោះ ។ **អ្នកស្រី ខ្លូត ផល្លា** ក្នុងនាមជាប្រធានគណៈកម្មធិការអភិវឌ្ឍន៍សហគមន៍ សែនសុខ ១ បាននិយាយដោយក្តីសោមនស្សថា៖ *លូថ្មីនេះអាចបង្កើតឡើងបានដោយមានការសហការដោយមនុស្សជាច្រើន។ ហើយនៅក្រោមការ សហការណ៍ទាំងនោះ គឺមានការចូលរួមគាំទ្រយ៉ាងខ្លាំងក្លា លើការកសាងសមត្ថភាព និងគំនិតផ្តួចផ្តើមរបស់ ស្តារ៍ ។*

គាត់បាននិយាយសង្កត់បន្ថែមទៀតថា ៖ *ប្រជាពលរដ្ឋឥលូវនេះ បានយល់ដឹងនូវសារៈសំខាន់ នៃការបញ្ចេញមតិរបស់ពួកគាត់ ដូច្នោះហើយពួកគាត់ ក៏បានចាប់ផ្តើមកំណត់នូវបញ្ហា ដែលត្រូវដោះស្រាយជាពិសេសអ្វីដែលសហគមន៍ អាចធ្វើបានដោយខ្លួនឯង ។*

មិនថាតាមរយៈការគាំទ្រផ្នែកស្មារតី ឬផ្នែករូបវន្ត ឬទាំងពីរនោះបូកបញ្ចូលគ្នាទេ ប្រជាពលរដ្ឋជាច្រើន និងអាជ្ញាធរក្នុងតំបន់ បានកំពុងចាប់ផ្តើមធ្វើការងារជាមួយគ្នា ។



លោក **កង ចក្រាវុធ**

# A New Sewer from Good Collaboration

Learning from **CSARO** awareness-raising and skill-based training on community development approaches, community people start to identify their own priority problems and seek potential solutions. They frame the scope of activity needed, where they can take part and find where they need support and assistance from the local authorities and/or civil society institutions.

Every year in rainy season, ***Sen Sok 4*** is unfortunate as water constantly floods the area, causing people to suffer from various water-borne diseases and a polluted stench from the rotting rubbish floating in the water. In the same way, it is very hard for people to work out transport and communicate during that period. As they jointly worked to solve this problem, people decided to develop a proposal to raise funds (on the 50-50 basis) from the local authorities, **CSARO** and local people alike to put in a sewer drainage system that can stop the community from being seriously flooded as it has been in previous years.

**Mr. Kong Chakra Vuth**, a member of Sen Sok community raised his concern, *"It was hard whenever rain came because the remaining water on the roads made it difficult to move or go anywhere far and it smelled really bad." He added that, "I was very happy when the proposal was considered and the drainage system was agreed for Sen Sok 4. I never thought that our communities could do it."*

After 2 months of collaborative work between local people, with support from the local authorities and **CSARO,** a new sewer was successfully erected, replacing the old one where piles of rubbish had blocked polluted water from being drained away. Hence, people do not have to be worried any longer of the flooded roads, bad smell and swamps during the rainy season.

Sen Sok 1 CDC Chief **Ms. Khloth Phalla** claimed with great delight:



Ms. Khloth Phalla

*"The new sewer was made possible by contributions from a lot of people and institutions ,and underlying this strong collaboration is CSARO's extensive support, capacity building and initiative."*

*"People are now aware of the importance of their voices and so they start to prioritize what problems should be handled next, especially what they as the community members can do,"* she stressed.

Either mentally or physically or both, most community people and the authorities now start to work together.



*New 150-metre sewer was erected in Sen Sok 4 community*

# ...ពីវត្ថុដែលគ្មានតម្លៃ ទៅជារបស់ដែលមានតម្លៃ...

ប្រាក់ចំណូលជាង ៣ ដុល្លា ក្នុង ១ ថ្ងៃ ជាមធ្យម មិនអាចធ្វើឲ្យជីវិតរបស់អ្នករើសសំរាម និងប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងនៃប្រទេសកម្ពុជាបានប្រសើរឡើងឡើយ ។ ដូច្នេះហើយ ក្រៅពីគោលបំណងធំជាចំបងរបស់ខ្លួន ក្នុងការលើកកំពស់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ **អង្គការស្ការ៉ូ** ក៏បានយកចិត្តទុកដាក់ជាខ្លាំងក្នុងការបំពាក់បំប៉នក្រុមអ្នករើសសំរាម ដែលខ្វះចំណេះដឹង និងហាក់ដូចជាមិនអាចឈានជើងចេញពីរង្វង់នៃភាពក្រីក្រនោះ នូវជំនាញដែលពួកគាត់ប្រាកដជានឹងត្រូវការ ដើម្បីធ្វើឲ្យគំរិតជីវភាពរស់នៅរបស់គាត់កាន់តែផ្លាស់ប្តូរទៅកាន់ភាពប្រសើរឡើង។ ជំនាញនៃការកែច្នៃសំរាមនិងការស្វែងរកទីផ្សារសំរាប់ផលិតផលរបស់ខ្លួន ត្រូវបានផ្តល់ជូនទៅពួកគាត់ ដើម្បីឲ្យពួកគាត់អាចយកសំរាមដូចជា ក្រដាស ផ្លាស្ទិច និងក្រណាត់ចាស់ ៗ ដែលរកបាននៅក្នុងសហគមន៍របស់គាត់ ទៅច្នៃជាផលិតផលដែលមានប្រយោជន៍ និងលក់ដើម្បីទទួលបានប្រាក់ចំណូលបន្ថែម ។ ពីរបស់ដែលគ្មានតម្លៃទៅជារបស់មានតម្លៃ និងពីគ្មានជំនាញទៅជាមានជំនាញ ពួកគាត់ចាប់ផ្តើមទទួលអារម្មណ៍ថាការផ្លាស់ប្តូរបានចូលមកដល់ ។ បើទោះបីជាប្រាក់ចំណូលមិនខ្ពស់ក្តី ផលិតផលទាំងនោះបានកកើតចេញមក ពីភាពច្នៃប្រឌិតរបស់ពួកគាត់ ហើយពួកគាត់ពេញចិត្ត នឹងចែករំលែកចំណេះទាំងនោះបន្តទៅបងប្អូន និងញាតិមិត្តជិតខាង ។



**អ្នកស្រី វង្ស សាវេន** អាយុ ៤៥ ឆ្នាំ ជាប្រជាពលរដ្ឋ ក្នុងសង្កាត់ឃ្មួញ នៃសហគមន៍ សែនសុខ បាននិយាយដោយមានជំនឿចិត្ត ដើម្បីបង្ហាញនូវទឹកចិត្តរីករាយរបស់គាត់ ជាមួយនឹងជំនាញថ្មីនៃការកែច្នៃក្រដាស និង ថង់កៅស៊ូដែលគាត់បានសិក្សាពីអ្នកជំនាញ របស់**ស្ការ៉ូ** ថា៖ *ពីមុនខ្ញុំមិនដែលមានគំនិតអ្វីមកធ្វើរឿងអញ្ចឹងនោះឡើយ ពីព្រោះមិនដែលមានអ្នកណាមក បង្រៀនឲ្យខ្ញុំចេះធ្វើវាទេតែនៅពេលដែលខ្ញុំបានចូលរួមជាមួយនឹងអង្គការ ស្ការ៉ូ ដូចដែលអ្នកបានឃើញស្រាប់ ខ្ញុំនិងអ្នកផ្សេងទៀតអាចធ្វើឲ្យវត្ថុទាំងនេះបានទៅជាគ្រឿងអលង្ការ ជាទំរង់រូបរាងផ្សេង ៗ ជាមួយនឹងពណ៌ចំរុះ ។ យើងបានព្យាយាមគិតថាតើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឲ្យរបស់ទាំងនេះអាចទាក់ភ្នែកអ្នកទិញបាន។* គាត់បានបន្ថែមទៀតថាផលិតផលនេះគឺមានទំរង់ និងម៉ូតថ្មី ៗ ហើយក្រោមការណែនាំ និងគំនិតច្នៃប្រឌិត ពួកគាត់បានផ្លាស់ប្តូរម៉ូត ឬការរចនា និងគុណភាពរបស់ផលិតផលនោះជាលំដាប់ ។

**អ្នកស្រី វង្ស សាវេន** ធ្លាប់បានមានប្រសាសន៍ថា គាត់អាចរកចំណូលបន្ថែមចំនួន ពី ៣០ ទៅ ៣៥ ដុល្លាក្នុងមួយខែពីផលិតផលកែច្នៃរបស់គាត់ ដែលគាត់គិតថា វាជាប្រាក់ចំណូលបន្ថែមពីប្រាក់ចំណូល របស់ប្តីគាត់ដែលបានពីការស៊ីឈ្នួលបើករថយន្តរត់ឈ្នួល ។

គាត់ជឿជាក់ថា៖ នឹងមានអង្គការដែលមានកម្មវិធីដូច **ស្ការ៉ូ** ផ្សេង ៗ ទៀតដែលនឹងផ្តល់ចំណេះដឹង និងចំណេះធ្វើតាមរយៈការផ្តល់ជាវគ្គបណ្តុះបណ្តាលដល់ពួកខ្ញុំ ដើម្បីឲ្យប្រជាពលរដ្ឋដែលខ្វះទីពឹង និងគ្មានសង្ឃឹមក្នុងជីវិតអាចទទួលបានឱកាស ក្នុងការកសាងជីវិតថ្មីមួយដែលប្រសើរជាងមុន ។

ដោយសារជីវភាពត្រូវបានផ្លាស់ប្តូរ មិនខុសពី **អ្នកស្រី សាវេន** ឡើយ ប្រជាពលរដ្ឋក្រីក្រ និងអ្នករើសអេតចាយ ឬអ្នកគ្មានការងារធ្វើមួយចំនួនធំ បានទទួលនូវក្តីសង្ឃឹមឡើងវិញ ហើយតាមការងារកែច្នៃសំរាមនេះពួកគាត់មានទឹកចិត្តមុះមុតក្នុងការជួយខ្លួនឯង ក៏ដូចជាជួយគ្រួសារ និងកូន ៗ របស់ពួកគាត់តាមការងារកែច្នៃ ។



### លក្ខណៈវិសេសរបស់កម្មវិធីអភិវឌ្ឍន៍សហគមន៍ទីក្រុង

- បន្ថែមទៅលើជំនាញ និងចំណេះដឹងដែលបានផ្តល់ជូននោះ អ្នករើសសំរាម និងប្រជាជនក្រីក្រកាន់តែមានភាពច្នៃប្រឌិតខ្ពស់ មានសកម្មភាពរស់រវើក រួមទាំងមានគំនិតផ្តួចផ្តើមក្នុងការផលិត និងកែច្នៃផលិតផលផ្សេង ៗ ដើម្បីរកប្រាក់ចំណូលបន្ថែម ដើម្បីធានាឲ្យបាននូវសន្តិសុខសេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់ ។

- ផ្លូវ និងប្រពន្ធ័លូបង្ហូរទឹកស្អុយថ្មីដែលបានសាងសង់ ឬជួសជុលបំពេញបន្ថែម មិនត្រឹមតែបានសំរួលដល់ការធ្វើដំណើរទៅមក និងលើកកំពស់បរិស្ថានល្អប៉ុណ្ណោះទេ តែវាក៏ជួយពង្រឹងនូវទំនាក់ទំនង និងកិច្ចសហការណ៍ល្អរវាងអជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីអាចបន្តសកម្មភាពអភិវឌ្ឍសហគមន៍របស់ពួកគេជាបន្តទៀត ។

# ... From Nothing to Something ...

An average income of less than 3 USD a day is simply not emough to provide a better life for waste pickers and poor urban community people in Cambodia. In addition to its major aim to improve the community environment, **CSARO** therefore has also put a great focus on equipping uneducated waste pickers who find no way to jump out of poverty with the necessary skills required to improve their living standard. Waste recycling and marketing skills are provided so that useless waste such as paper, plastics and old clothes available in the community can be transferred into useful products and sold for an income. In this way, waste pickers and urban community poor can start to help themselves and their families through recycling programs that promote social and economic security. From changing useless objects to useful products and from changing unskilled workers to skillful small business operators, a real sense of change emerges. The income is not huge, the products come out of participants creativity but the result is significant, and participants love to share the skills to their relatives and neighbors.

**Ms. Vong Saven**, 45, of Sen Sok community's Khmournh commune spoke with confidence to express how delighted she is with her new skills taught by specialists from **CSARO** in recycling paper and plastic wastes she sold for an income: *"I do not have any idea to make such things before I joined with CSARO because no one guides me to, but now, as you can see, I and others can make these colorful strands of jewelry coming in various forms. We just try to make it attractive for different clients."* She added that the products are of new styles and they kept, under the guidance and with creativity, changing their styles and quality.

Saven can earn from 30 to 35 USD a month from her recycled products, which she thinks is another safe alternative way of earning an income additional to her husband's revenue from taxi driving. Saven believes, "There will be more such organizations to provide knowledge and know-how through training to us, so that the destitute people and hopeless waste pickers will have the opportunity to live a better life."

As life changes, like Saven, many other waste pickers and jobless people gain new hope and their resilience grows a bit stronger, supporting their ability to function well. Some help not only themselves but also their children and their relatives from their recycling of waste.





***Urban Community Development Program (UCDP) Significant Features:***

- ***In addition to the skills and knowledge provided, waste pickers become more creative, proactive and resourceful in producing and recycling waste into useful products to earn an income, to ensure their families economy security.***

- ***New drainage and roads not only allow good transportation and improve the environment, but they start to enhance relationships and communication between the local authorities and the community people to further instigate development activities for their communities.***

# ជួយប្រជាពលរដ្ឋផង ជួយបរិស្ថានសហគមន៍ផង

## *នៅពេលដែលក្រុមជួយខ្លួនឯងបានមកដល់*

ក្រុមមួយដែលមានសមាជិក ១០ នាក់ ក្នុងនោះមានស្រ្តី ៨ នាក់ ដែលជាអតីតអ្នករើសសំរាមក្នុងទីក្រុងស្ទឹងត្រែង ត្រូវបានបង្កើតឡើងនៅខែមិនា ឆ្នាំ ២០១០ ដោយបានគំនិតផ្តួចផ្តើមពី អង្គការ **ស្តារ៍** ។ សមាជិកនៃក្រុមនេះ គឺជាអ្នកទទួលផលផ្ទាល់ពីគំរោង ដោយពួកគាត់បានចាប់ផ្តើម ធ្វើការងារនៅខែ ឧសភា ឆ្នាំ ២០១០ ដោយដើរប្រមូល សំរាមបឋមពីតាមផ្ទះ និងធ្វើការបែងចែកទៅតាមប្រភេទបានយ៉ាងល្អ។ ក្រុមនេះជា **ក្រុមជួយខ្លួនឯង** ដែលធ្វើការងារពី ថ្ងៃ ចន្ទ័ ដល់ សៅរ៍ និងចាប់ពី ម៉ោង ៦ ព្រឹក រហូតដល់ពួកគាត់បញ្ចប់ការងាររបស់គាត់តាមគំរោងដោយរាប់បញ្ចូលទាំងភារកិច្ច លាងសម្អាតរទេះ និងធុងសំរាម និងថែរក្សានូវសម្ភារៈ ផ្សេង ៗ ដែលស្តារ៍ បានផ្តត់ផ្គង់ ។

**អ្នកស្រី សែ សុខាវី** ដែលជាគ្រូបង្រៀនថ្នាក់បឋមសិក្សានៅ សាលាបឋមសិក្សា ស្ទឹងត្រែង ហើយក៏ជាប្រជាពលរដ្ឋមួយរូបរស់ នៅក្នុង ភូមិស្ពានថ្មក្រុង ស្ទឹងត្រែង បានថ្លែងថា៖ *មុនពេលដែលមានវត្តមានរបស់ក្រុមរើសសំរាមដែលមានឯកសណ្ឋានព៌ណលឿងនោះ អ្នកភូមិគាត់ប្រមូលសំរាមដោយខ្លួនឯង ហើយដុតសំរាមនោះចោលនៅក្នុងទីណាមួយក្នុងបរិវេណជុំវិញផ្ទះ ដែលវាធ្វើឲ្យប៉ះពាល់ដល់បរិស្ថានខ្លាំងណាស់ ។ ពិសេសនៅពេលភ្លៀងធ្លាក់ សំរាមដែលមិនទាន់ឆេះនោះបានបំភាយក្លិនមិនល្អដល់ការដកដង្ហើមរបស់មនុស្សម្នា ។*

*ឥលូវវាមិនពិបាកដូចមុនទៀតទេតាំងពី ក្រុមជួយខ្លួនឯងនេះ បានមកដល់ ព្រោះអ្នកស្រុកគ្រាន់តែប្រមូលសំរាមដាក់ក្នុងថង់ និងយកទៅដាក់នៅមុខផ្ទះខ្លួនប៉ុណ្ណោះ បន្ទាប់មកក្រុមនេះក៏មកប្រមូលសំរាមនោះទៅ* ។ អ្នកស្រី **សុខាវី** បានបញ្ជាក់បន្ថែមយ៉ាងដូច្នោះដោយនិយាយទៀតថា ប្រជាពលរដ្ឋ ភូមិស្ពានថ្ម ទាំងមូលមិនចាំបាច់បារម្ភពីខ្លិនស្អុយ ឬ ផ្សែងពុលពីការដុតសំរាមដូចមុនទៀតឡើយ ។

**អ្នកស្រី សុខាវី** ក៏ធ្លាប់បានចូលរួមក្នុងការធ្វើទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍របស់ ស្តារ៍ ទៅកាន់សហគមន៍ក្នុងក្រុងភ្នំពេញ ហើយគាត់បានគូសបញ្ជាក់ថា៖ *ខ្ញុំឃើញមនុស្សមួយក្រុមមកប្រមូលសំរាមពីតាមផ្ទះ ។ វាពិតជាជួយសម្រួលដល់អ្នកស្រុកខ្លាំងណាស់ ហើយពួកគាត់មិនចាំបាច់បារម្ភខ្លាំងពីបញ្ហាសុខភាព និងបរិស្ថាន ។ ដូច្នេះខ្ញុំចាប់ផ្តើមមានគំនិតចាប់ពីពេលនោះថា ខ្ញុំចង់ឲ្យខេត្ត ស្ទឹងត្រែង ធ្វើនូវរឿងដូចគ្នានេះ គឺការផ្តល់សេវាប្រមូលសំរាម ។ ហើយឥលូវនេះ ខ្ញុំឃើញនូវអ្វីដែលខ្ញុំតែងតែចង់ឃើញនោះហើយ ។*

ក្នុងទិសដៅនៃការបង្កើតក្រុមជួយខ្លួនឯងនេះ **អង្គការ ស្តារ៍** មានបំណងឲ្យសាធារណៈជន អជ្ញាធរក្នុងតំបន់ និងសហគមន៍ ទទួលស្គាល់នូវតម្លៃនៃក្រុមអ្នករើស និងប្រមូលសំរាម និងកាត់បន្ថយការរើសអើង និងការយល់ឃើញបែបទុទិដ្ឋិនិយមទៅលើពួកគាត់ ពីសំណាក់មជ្ឈដ្ឋានដែលរស់នៅជុំវិញពួកគាត់ ។



គោលដៅសំខាន់មួយទៀត គឺជួយបង្កើន ប្រាក់ចំណូលរបស់ក្រុមនេះ បន្ថែមទៅលើចំណូលពីការងារ ដែលគាត់មានស្រាប់ ដើម្បីឲ្យពួកគាត់កាន់តែមានគំរិតជីវភាពរស់នៅល្អប្រសើរឡើង ។

យោងទៅតាមទស្សនៈរបស់ ក្រុមជួយខ្លួនឯងវិញ ពួកគាត់ក៏ជឿជាក់យ៉ាងមុតមាំ ថាការងាររបស់គាត់គឺមានសារៈសំខាន់ដោយសារតែគាត់ អាចធ្វើការបាន យ៉ាងល្អជាមួយគ្នាក្នុងការជួយសម្អាតបរិស្ថានក្នុងសហគមន៍ និងអាចរកចំណូលបានទៀត ។ ហើយពួកគាត់ក៏មិនត្រូវបានអ្នកផ្សេងមើលងាយដូចមុនដែរ ។

*ឥលូវនេះ ពួកយើងត្រូវបានជាប់ឈ្មោះជាៈអ្នកជួយសម្អាតអនាម័យទីក្រុង និងបរិស្ថាន ដូច្នេះយើងប្តេជ្ញានឹងបន្តការងារឲ្យបានជោគជ័យបន្ថែមទៀត នៅពេលដែលយើងនៅតែទទួលបានការគាំទ្រ ពី* ***ស្តារ៍*** នេះបើតាម សម្តី អ្នកស្រី **ថន សុជាតិ** ដែលជាប្រធាន ក្រុមពាក់អាវលឿង នេះ ។



## LESSONS LEARNED

During 2010, **CSARO** continued to reflect and learn important lessons for its future growth:

- A variety of participants including community residents, disadvantaged groups such as waste pickers, and the local authorities can both enhance the network and evoke the sense of responsibility to engage and ensure the community development course of action.

- Increasing innovation and creativity of products made of unvalued waste means changing styles, quality and durability of the products to enlarge the market share.

- Waste pickers and other beneficiaries who attend the training will distribute the knowledge further to their children, relatives, or friends working in other institutions, which ensures an increased concentration of indirect **CSARO** beneficiaries.

- Staff capacity building through important training courses provides more advanced knowledge for an effective outcome, increases collaborative problem solving, enhances teamwork spirit and builds good networks with other development partners' officials.

## CHALLENGES

In the practical implementation of the work to develop Cambodian society and itself, **CSARO** inevitably faces various key challenges, namely:

- Products made of waste have not been much valued by customers, compared to the same products made of other materials.

- Compost market shares, compared to that of the chemical fertilizers, remain narrower as some business-minded people still value profits more than the environment and health.

- The urban community needs many more key inputs such as good governance, enhanced education, food and job security and infrastructural development for a better economic growth and social development.

- The impact of global financial crisis remains strong in the lifes of youth, of the urban community poor and disadvantaged groups and waste pickers.

- The number of child waste pickers who return to school is still are very limited.

## FUTURE DIRECTIONS

Through extensive experience and lessons-learnt from 2010 and previous years, **CSARO** is highly determined and committed to make the following important steps forward for the encouragement of institutional and social development:

- To developing strategic frameworks that help increase the market share of recycled products and compost through the integration of great quality and an expansion of target areas, so as to provide better income generation opportunities for the community.

- Continue to provide necessary supports to waste pickers and community people, both technical and material, and learning support through training workshops, so they can get engaged and help themselves to grow and develop well.

- To restructure and enlarge the scope of educational support activities to child waste pickers to ensure that more of them will return to formal education.

- To continue to enhance staff capacity, encourage their contribution through motivation, and allow them to gain access to more advanced and diversified skill training courses so as to work better in a collaborative, devoted and honest manner.



# បុគ្គលិករបស់ ស្តារ៉ូ

## ការិយាល័យនៅភ្នំពេញ

| | |
|---|---|
| លោក ហេង យ៉ុនគ្វ៉ា | នាយកប្រតិបត្តិ |
| កញ្ញា អៀម សុខនី | មន្ត្រីរដ្ឋបាល និងគណនេយ្យ |
| លោក ងួន វណ្ណា | បុគ្គលិករដ្ឋបាលនិង គណនេយ្យ |
| លោក នាង វណ្ណី | ជំនួយការការិយាល័យ/ រៀបពិធីការ |
| លោកស្រី ស៊ឹម ប៊ុនសៀម | អ្នកបោសជូត |

## កម្មវិធីនៅភ្នំពេញ

| | |
|---|---|
| លោក សេង សុខសាន្ត | អ្នកសម្របសម្រួលកម្មវិធី |
| លោក ញិប ធី | មន្ត្រីកម្មវិធី |
| លោកស្រី តូច បុប្ផា | អ្នកសម្របសម្រួលសហគមន៍ |
| លោក សូ វណ្ណថាច | អ្នកសម្របសម្រួលសហគមន៍ |
| លោក គុក សារ៉ន | អ្នកសម្របសម្រួលសហគមន៍ |
| កញ្ញា ស្រ៊ិន សុខមាន | អ្នកធ្វើការសង្គម |
| កញ្ញា ឌុច ចន្ថា | អ្នកធ្វើការសង្គម |
| លោក ឈុន ពុទ្ធី | អ្នកបើកបរ/រៀបពិធីការ |
| កញ្ញា លី នីម៉ូនីកា | អ្នកធ្វើការសង្គម |
| លោក ប្រាក់ មុន្នី | សន្តិសុខ |
| លោក ផេត សុភាព | អ្នកបោសជូតមណ្ឌល |
| លោក កែវ វឿន | សន្តិសុខ |
| លោក សិប វីរៈ | អ្នកបើកបរឲ្យមណ្ឌល |

## គំរោងនៅខេត្ត ស្ទឹងត្រែង

| | |
|---|---|
| លោក នួន សំណាង | អ្នកសម្របសម្រួលកម្មវិធី |
| លោក នៅ ហៀង | មន្ត្រីកម្មវិធី |
| កញ្ញា ហ៊ឹម ចិន្តា | ជំនួយការរដ្ឋបាល និងគណនេយ្យ |
| លោក ហេង សារ៉េត | អ្នកសម្របសម្រួលសហគមន៍ |
| លោក ពៅ សំអន | អ្នករចនា |
| លោក កែវ សំណាង | អ្នកបើកបរ/រៀបពិធីការ |
| លោក សាន ដេវីដ | សន្តិសុខ |
| លោក ហ៊ឹ រិទ្ធ | សន្តិសុខ |



# CSARO STAFF

## *Office in Phnom Penh*

| | |
|---|---|
| **Mr. Heng Yon Kora,** | Executive Director |
| **Ms. Eam Sokny,** | Accounting and Administration Officer |
| **Mr. Ngoun Vanna,** | Accounting and Administration Staff |
| **Mr. Neang Vanny,** | Office Assistant/Logistic |
| **Ms. Sum Bunsiem,** | Office Cleaner |

## *Programs in Phnom Penh*

| | |
|---|---|
| **Mr. Seng Soksan,** | Program Coordinator |
| **Mr. Nhep Thy,** | Program Officer |
| **Ms. Touch Bopha,** | Community Facilitator |
| **Mr. So Vanthach,** | Community Facilitator |
| **Mr. Kok Saron,** | Community Facilitator |
| **Ms. Srun Sokmean,** | Social Worker |
| **Ms. Duch Chantha,** | Social Worker |
| **Mr. Chhun Puthy,** | Driver/Logistic |
| **Ms. Li Nimonika,** | Social Worker |
| **Mr. Prak Mony,** | Security Guard |
| **Mr. Cheit Sopheap,** | Center Cleaner |
| **Mr. Koe Voeun,** | Security Guard |
| **Mr. Sip Virak,** | Center Driver |

## *Projects in Stung Treng*

| | |
|---|---|
| **Mr. Nuon Samnang,** | Program Coordinator |
| **Mr. Nov Hieng,** | Program Officer |
| **Ms. Him Chenda,** | Accounting and Administration Assistant |
| **Mr. Heng Sareth,** | Community Facilitator |
| **Mr. Pov Sam On,** | Designer |
| **Mr. Keo Samnang,** | Driver/Logistic |
| **Mr. San Davith,** | Security Guard |
| **Mr. Hum Rith,** | Seurity Guard |



# ស្ថានភាពហិរញ្ញវត្ថុ

## អង្គការកែច្នៃ និងអនាម័យសហគមន៍

*របាយការណ៍ចំណូល ចំណាយ និងសមតុល្យថវិកា*
*ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០*

| | 2010<br>ដុល្លា | 2009<br>ដុល្លា |
|---|---|---|
| • សមតុល្យដើមគ្រា | | |
| សាច់ប្រាក់ក្នុងដៃ | 654.00 | 122.00 |
| សាច់ប្រាក់ក្នុងធនាគារ | 43,426.00 | 24,073.00 |
| | 44,080.00 | 24,195.00 |
| • ប្រភពធនធាន | | |
| *ប្រភពពីម្ចាស់ជំនួយ* | | |
| MISEREOR | 24,676.10 | 69,759.00 |
| MANOS UNIDAS | 34,830.42 | 113,167.00 |
| Scottish Catholic International Aid Fund ( SCIAF ) | 27,763.18 | 21,356.00 |
| Global Fund for Children ( GFC ) | 9,000.00 | 5,000.00 |
| *ជំនួយផ្សេង ៗ ដែលទទួលបាន* | 14,432.83 | 2,446.00 |
| ធនធានទទួលបានសរុប | 110,702.53 | 211,728.00 |
| | $154,782.53 | $235,923.00 |
| • ការចំណាយ | | |
| កម្មវិធីអភិវឌ្ឍន៍សហគមន៍ទីក្រុង | 24,106.58 | 24,451.00 |
| កម្មវិធីគ្រប់គ្រងសំណល់រឹង | 36,291.44 | 23,321.00 |
| កម្មវិធីអប់រំផ្សព្វផ្សាយចល័ត | 31,716.07 | 31,208.00 |
| កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន | 32,235.50 | 29,648.00 |
| ការពិនិត្យ និងវាយតម្លៃ | 11,897.56 | 7,507.00 |
| មណ្ឌលអ្នករើសសំរាម | 0.00 | 75,708.00 |
| ការចំណាយសរុប | 136,247.15 | 191,843.00 |
| • សមតុល្យចុងគ្រា | | |
| សាច់ប្រាក់ក្នុងដៃ | 542.43 | 654.00 |
| សាច់ប្រាក់ក្នុងធនាគារ | 17,992.95 | 43,426.00 |
| | 18,535.38 | 44,080.00 |
| | $ 154,782.53 | $235,923.00 |

## របាយការណ៍
## ការចំណាយសំរ




**FINANCIAL S**
**Use of Fund in**

# Financial Status

*Community Sanitation and Recycling Organization*
*Statement of Revenues, Expenditures and Changes in Fund Balance*
*For the year ended 31 December 2010*

ាសង្ខេប
ាប់ឆ្នាំ ២០១០




UMMARY
2010

| | 2010 USD | 2009 USD |
|---|---|---|
| • OPENING BALANCE | | |
| Cash on Hand | 654.00 | 122.00 |
| Cash in Bank | 43,426.00 | 24,073.00 |
| | **44,080.00** | **24,195.00** |
| • RECEIPTS FOR THE YEAR | | |
| *Funds Received from Donors* | | |
| MISEREOR | 24,676.10 | 69,759.00 |
| MANOS UNIDAS | 34,830.42 | 113,167.00 |
| Scottish Catholic International Aid Fund (SCIAF) | 27,763.18 | 21,356.00 |
| Global Fund for Children (GFC) | 9,000.00 | 5,000.00 |
| *Miscellaneous Receipts* | 14,432.83 | 2,446.00 |
| TOTAL RESOURCES | **110,702.53** | **211,728.00** |
| | **$154,782.53** | **$235,923.00** |
| • EXPENDITURE | | |
| Urban Community Development Program | 24,106.58 | 24,451.00 |
| Solid Waste Management Program | 36,291.44 | 23,321.00 |
| Mobile Outreach Education Program | 31,716.07 | 31,208.00 |
| Institutional Development Program | 32,235.50 | 29,648.00 |
| Monitoring and Evaluation | 11,897.56 | 7,507.00 |
| Waste Picker Center | 0.00 | 75,708.00 |
| TOTAL EXPENDITURE | **136,247.15** | **191,843.00** |
| • CLOSING BALANCE | | |
| Cash on Hand | 542.43 | 654.00 |
| Cash in Bank | 17,992.95 | 43,426.00 |
| | **18,535.38** | **44,080.00** |
| | **$154,782.53** | **$235,923.00** |











# រូបថតសកម្មភាព សំខាន់ ៗ របស់ ស្ការូ ឆ្នាំ ២០១០

























# Photos of CSARO 2010 Key Activities











# ម្ចាស់ជំនួយរបស់ ស្ការ៉ូ

THE GLOBAL FUND FOR Children

Manos Unidas

# ស្ថាប័នជាដៃគូ របស់ ស្ការ៉ូ

- **គណកម្មាធិការសហប្រតិបត្តិការកម្ពុជា**
- **វេទិកាអង្គការមិនមែនរាជរដ្ឋាភិបាលកម្ពុជា**
- **អង្គការធ្វើការជាមួយសហគមន៍ទីក្រុង**
  - *អភិបាលក្រុង*
  - *ក្រុមប្រឹក្សាឃុំ សង្កាត់*
  - *មេភូមិ*
  - *គណៈកម្មាធិការសាលាប្រចាំភូមិ*
  - *គណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ទីក្រុង*
- **ព្រះរាជាណាចក្រកម្ពុជា**
  - *ក្រសួងមហាផ្ទៃ*
  - *ក្រសួងបរិស្ថាន*
- **រដ្ឋាភិបាលថ្នាក់ខេត្ត និងថ្នាក់ជាតិរបស់ព្រះរាជាណាចក្រកម្ពុជា**
  - *សាលាក្រុងភ្នំពេញ*
  - *សាលាខេត្តស្ទឹងត្រែង*
  - *មន្ទីរបរិស្ថានខេត្តស្ទឹងត្រែង*
  - *នាយកដ្ឋានអប់រំ ទីក្រុងភ្នំពេញ*

## CSARO's Donor

SCIAF
SCOTTISH CATHOLIC INTERNATIONAL AID FUND

MISEREOR

## CSARO's Partners

- **CCC – Cooperation Committee for Cambodia**
- **NGO Forum on Cambodia**
- **Urban Community-Based Organization (UCBOs)**
  - *City Governors*
  - *Commune Councils*
  - *Village Leaders*
  - *Village School Committees*
  - *Urban Community Development Committees*
- **Kingdom of Cambodia**
  - *Ministry of Interior*
  - *Ministry of Environment*
- **Kingdom of Cambodia national and provincial government**
  - *Municipality of Phnom Penh*
  - *Municipality of Stung Treng*
  - *Department of Environment Stung Treng*
  - *Department of Education Phnom Penh*

***CSARO's center:***

*Sangkat Kmounh, Khan SEN SOK, Phnom Penh, Cambodia*
*Contact:* **Mr. Heng Yon Kora,** *Executive Director*
*Tel: (855) 23 880 113/ Mobile Phone: (855) 12 217 747*

*Email: csaro@online.com.kh or info@scaro.org*
*http://www.online.com.kh/users/csaro or www.scaro.org*



**មណ្ឌលអង្គការ ស្ការ៉ូ**

សង្កាត់ឃ្មួញ ខណ្ឌ សែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទំនាក់ទំនង: លោក **ហេង យ៉ុនគូរ៉ា** នាយកប្រតិបត្តិ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៨០ ១១៣
ទូរស័ព្ទដៃ: (៨៥៥) ១២ ២១៧ ៧៤៧

អ៊ីមែល: csaro@online.com.kh | info@csaro.org
http://www.online.com.kh/users/csaro | www.csaro.org